# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ៧០០.កយ.ព្រទ-២០០៥

# រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

លោកប្រធានតុលាការខេត្ត-ក្រុង

លោកព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង

**កម្មវត្ថុ:** អំពីការចោទប្រកាន់ និងការផ្តន្ទាទោសជនប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទ ។

ខ្ញុំសូមជម្រាប លោក-លោកស្រីថា បច្ចុប្បន្នអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ កំពុងរីករាលដាលស្ទើរគ្រប់ទីកន្លែងទាំងអស់ទាំងនៅទីក្រុង និងជនបទ ដែលបង្កនូវចរិកគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរដល់សង្គមជាតិទាំងមូល ។

ករណីនេះ ក្រោយពីក្រសួងបានពិនិត្យនូវរបាយការណ៍ និងស្ថិតិប្រចាំខែរបស់តុលាការ និងអយ្យការគ្រប់ខេត្ត-ក្រុង ក្រសួងបានកត់សម្គាល់ឃើញថា ចំពោះការចោទប្រកាន់ និងការផ្តន្ទាទោស ជនល្មើសពីបទជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទនៅមានចំនួនតិចនៅឡើយ ហើយមិនទាន់បានផ្តន្ទាទោសអតិបរមានៃទោសដែលមានកំណត់ក្នុងច្បាប់នោះទេ ។

ដើម្បីកាត់បន្ថយនូវអំពើល្មើសបែបនេះ និងថែរក្សា សន្តិសុខ សណ្តាប់ធ្នាប់សង្គមធានានូវ ភាពយុត្តិធម៌ជូនប្រជាពលរដ្ឋ ដោយផ្អែកលើច្បាប់ឱ្យទទួលបាននូវលទ្ធផលល្អ ប្រកបដោយប្រសិទ្ធិភាពខ្ពស់ ។

អំណើះតទៅ លោកព្រះរាជអាជ្ញា និងលោក-លោកស្រី ប្រធានតុលាការ ត្រូវយកចិត្តទុកដាក់ក្នុងការបង្ក្រាបបទល្មើសបែបនេះឱ្យបានហ្មត់ចត់ជាទីបំផុត ដោយសម្រេចចោទប្រកាន់ និងផ្តន្ទាទោស ជាអតិបរមានៃទោសដែលមានកំណត់ក្នុងច្បាប់ ចំពោះគ្រប់ជនទាំងឡាយណា ដែលបានប្រព្រឹត្តអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

ក្រសួងសង្ឃឹមថា អស់លោក-លោកស្រី ប្រធានតុលាការ និងលោកព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុងទាំងអស់ នឹងយកចិត្តទុកដាក់អនុវត្តតាមការណែនាំនេះ ឱ្យបានល្អប្រសើរ និងមានប្រសិទ្ធិភាពខ្ពស់ ។

ភ្នំពេញ ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៥

**រដ្ឋមន្ត្រី**

**អង្គ វង្សវឌ្ឍានា**

ចម្លងជូន

-តុលាការកំពូល និង មហាអយ្យការអមតុលាការកំពូល
-សាលាឧទ្ធរណ៍ និង មហាអយ្យការអមសាលាឧទ្ធរណ៍
-ដើម្បីជ្រាប
-ឯកសារ-កាលប្បវត្តិ